ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
លេខ : 308 សក.បយ

ភ្នំពេញ,ថ្ងៃទី 26 ខែ តុលា ឆ្នាំ ១៩៩៩

# ប្រកាស
## ស្តីពីការបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ (ក.ស.ព)

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកត / ០៦៩៩ /០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានឃើញលិខិតតែងតាំងតំណាងរបស់ក្រសួងអប់រំ យុវជននិងកីឡាលេខ ៣៧០ អយក.រប ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩
- បានឃើញ លិខិតតែងតាំងតំណាងរបស់ក្រសួងសុខាភិបាលលេខ ១២ សខ.ល ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៩
- យោងសេចក្តីប្រកាសរបស់អង្គការ ESCAP ស្តីពីការចូលរួមយ៉ាងពេញលេញ និង សមភាពរបស់ជនពិការនៅក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក ដែលរាជរដ្ឋាភិបាលកម្ពុជាជាហត្ថលេខី
- យោងរបាយការណ៍របស់ក្រុមការងារពិសេស ស្តីពីយុទ្ធសាស្ត្រជាតិលើវិស័យស្តារលទ្ធភាពពលកម្មចំពោះបញ្ហាពិការភាពនៃក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន និង អង្គការក្រៅរដ្ឋាភិបាលឆ្ពោះទៅរកការធ្វើសមាហរណកម្មជនពិការទៅក្នុងសង្គមកម្ពុជា ខែតុលា ឆ្នាំ ១៩៩៦

- យោងលក្ខន្តិកៈរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ
- យោងសំណើរបស់គណៈកម្មការសកម្មភាពជនពិការ

# សំរេច

ប្រការ ១.. បង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ -ជាស្ថាប័នអចិន្ត្រៃយ៍មួយពាក់កណ្តាលរដ្ឋាភិបាល និងពាក់កណ្តាលមិនមែនរដ្ឋាភិបាល ដើម្បីជំនួសគណៈកម្មការសកម្មភាពជនពិការដែលត្រូវបានបញ្ចប់អាណត្តិ។

ប្រការ ២.. ក្រុមប្រឹក្សាភិបាលនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវមានសមាជិកមិនតិចជាង ៩នាក់ ហើយមិនលើសពី ១០នាក់ឡើយសំរាប់រយៈពេល ៣ឆ្នាំ។ ក្រុមប្រឹក្សានេះ ត្រូវបង្កើតឡើងដោយមានតំណាង ៥រូប មកពីខាងរដ្ឋាភិបាលកម្ពុជា ៣រូប គឺជាជនពិការតំណាងឱ្យអង្គការក្នុងស្រុកដែលបានចុះបញ្ជីជាមួយក្រសួងសង្គមកិច្ច និងមានសកម្មភាពពាក់ព័ន្ធជាមួយបញ្ហាពិការភាព និង ៣រូបទៀតជាតំណាងមកពីអង្គការអន្តរជាតិ ដែលបានចុះបញ្ជីជាមួយក្រសួងសង្គមកិច្ច និងមានសកម្មភាពពាក់ព័ន្ធជាមួយបញ្ហាពិការភាព។

សមាសភាពនិងការកាន់កាប់មុខតំណែងនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាភិបាលបច្ចុប្បន្នមានចែងនៅក្នុងឧបសម្ព័ន្ធ ១ ដែលភ្ជាប់ជាមួយឯកសារនេះ។

ប្រការ ៣.. ក្រុមប្រឹក្សាសកម្មភាពជនពិការដើរតួនាទីក្នុងសមត្ថកិច្ចជាអ្នកពិគ្រោះយោបល់ជំនាញទៅលើបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងសុខមាលភាពជនពិការ ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាល អ្នកតាក់តែងគោលនយោបាយ និងតំណាងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ ក្រុមប្រឹក្សានេះ ជាស្ថាប័នបំរើថ្នាក់ជាតិដែលផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាពិការភាព ដោយធ្វើការសំរបសំរួល ដើម្បីបន្តការរៀបចំយុទ្ធវិធីថ្នាក់ជាតិដ៏ទូលំទូលាយមួយ សំរាប់ការស្តារលទ្ធភាពពលកម្ម ការផ្តល់ឱកាសស្មើភាពគ្នា និងការទប់ស្កាត់ពិការភាព។

ប្រការ ៤.. ក្រុមប្រឹក្សាសកម្មភាពជនពិការ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម:

- ផ្តល់ការពិគ្រោះយោបល់ស្តីពីគោលនយោបាយដែលពាក់ព័ន្ធទៅនិងការអភិវឌ្ឍន៍ និងគាំទ្រដល់សេវាកម្មនានាសំរាប់ជនពិការ។
- ផ្តល់ការពិគ្រោះយោបល់ស្តីពីកម្មវិធី និងថវិកាសំរាប់អនុវត្តផែនការសកម្មភាព។
- សំរេចរាល់បញ្ហានិងសកម្មភាពដែលប្រព្រឹត្តទៅក្រោមក្របខ័ណ្ឌនៃលក្ខន្តិកៈរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ។

ប្រការ ៥.. ប្រធានក្រុមប្រឹក្សាភិបាល ត្រូវដឹកនាំរាល់អង្គប្រជុំរបស់ក្រុមប្រឹក្សា។ នៅពេលដែលប្រធានអវត្តមាន អនុប្រធាននឹងត្រូវដឹកនាំអង្គប្រជុំជំនួស។ នៅពេលដែលប្រធាន និងអនុប្រធានអវត្តមានទៀតនោះ សមាជិកម្នាក់នៅក្នុងចំណោមសមាជិកដែលមានវត្តមាននៅក្នុងអង្គប្រជុំ ត្រូវជ្រើសតាំងឱ្យដឹកនាំជំនួស។

បញ្ហាដែលបានស្នើឡើងក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល នឹងត្រូវអនុម័តយកតាមសំលេងភាគច្រើននៃសមាជិកដែលមានវត្តមាន និងដោយធ្វើការបោះឆ្នោតតាមលក្ខណៈសាមញ្ញ។ នៅពេលណាមានសំលេងស្មើគ្នា អ្នកដឹកនាំអង្គប្រជុំនឹងត្រូវបានគេប្រគល់សិទ្ធិឱ្យបន្ថែមសន្លឹកឆ្នោតទី២របស់ខ្លួន ឬ មានសិទ្ធិជាអ្នកសំរេច។

ប្រការ ៦.. សមាជិករូបណាដែលមិនអាចមកចូលរួមប្រជុំបាន មានសិទ្ធិតែងតាំងអ្នកតំណាងរបស់ខ្លួនមកចូលរួមប្រជុំ ប៉ុន្តែអ្នកតំណាងនោះពុំមានសិទ្ធិបោះឆ្នោតឡើយ។ ទោះជាយ៉ាងណាក្តី សមាជិកអវត្តមានរូបនោះមានសិទ្ធិផ្តល់មតិយោបល់របស់ខ្លួនពាក់ព័ន្ធទៅនឹងប្រធានបទនៃការពិភាក្សាមកកាន់អង្គប្រជុំសំរាប់រួមចំណែក ដល់ការធ្វើសេចក្តីសំរេចរបស់អង្គប្រជុំ។ ម្យ៉ាងទៀត ត្រូវជំរាបជូនដំណឹងដល់ប្រធានក្រុមប្រឹក្សាជាលាយលក្ខអក្សរយ៉ាងហោចណាស់ ១សប្តាហ៍មុន។

សមាជិកដែលអវត្តមានពុំបានមកចូលរួមប្រជុំចាប់ពី បី(៣)ដងឡើងទៅ នឹងត្រូវបានគេស្នើឱ្យបញ្ជាក់ពីមូលហេតុរបស់ខ្លួន។ សមាជិកទាំងនោះ អាចត្រូវបានផ្លាស់ប្តូរតាមសំណើរបស់ខ្លួន ឬតាមការបោះឆ្នោតអនុម័ត ដោយមតិភាគច្រើននៃសមាជិកក្រុមប្រឹក្សា។

ប្រការ ៧.. ក្រុមប្រឹក្សាភិបាលត្រូវជួបប្រជុំគ្នាពីរខែម្តង ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាដែលលើកឡើងដោយ គណៈកម្មការបច្ចេកទេស និងគណៈកម្មការជំនាញ និងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សា ហើយនិងផ្តល់ដោយផ្ទាល់ ឬ តាមរយៈលេខាធិការដ្ឋាននូវការណែនាំទិសដៅការគ្រប់គ្រង និងការសំរេច។

ប្រការ ៨.. ក្រុមប្រឹក្សាភិបាលមានសិទ្ធិតែងតាំងនាយកប្រតិបត្តិនៃលេខាធិការដ្ឋានក្រុមប្រឹក្សាដើម្បីទទួលខុសត្រូវជាទូទៅចំពោះការគ្រប់គ្រង និងប្រតិបត្តិការលេខាធិការដ្ឋាន ហើយនិងពិនិត្យតាមដាន និងវាយតំលៃការងាររបស់លេខាធិការដ្ឋាន។

ការងារបច្ចេកទេសទាំងឡាយ ត្រូវរៀបចំ និងអនុវត្តដោយគណៈកម្មការបច្ចេកទេស និងគណៈកម្មការជំនាញរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ និងអង្គការជាសម្ព័ន្ធភាពរបស់ក្រុមប្រឹក្សា។

ប្រការ ៩.. ក្រុមប្រឹក្សាសកម្មភាពជនពិការមានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ក្រុមប្រឹក្សា។

ប្រការ ១០.- រាល់សេចក្ដីសំរេចពីមុនមកដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ១១.- សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ដូចមានចែងនៅក្នុងប្រការ ២ ត្រូវអនុវត្តខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>កន្លែងទទួល:</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីជ្រាបជាពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- អង្គការពាក់ព័ន្ធជាតិ និងអន្តរជាតិ
- អង្គភាពក្រោមឱវាទក្រសួង
- សមាជិកក្រុមប្រឹក្សាភិបាល
- ឯកសារ . កាលប្បវត្តិ

## បញ្ជីឧបសម្ព័ន្ធនៃប្រកាសលេខ ៣០៨ សកបយ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩

សមាសភាព និង ការកាន់មុខតំណែងនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាភិបាលបច្ចុប្បន្ន រួមមាន :

| | | | |
|---|---|---|---|
| ១-លោកជំទាវ | ប្រាក់ ចន្ទា | រដ្ឋលេខាធិការក្រសួងសកបយ | ជាប្រធាន |
| ២-លោក | ខា សុន ហាត | នាយកប្រចាំប្រទេស អង្គការ CT/CSPO | ជាអនុប្រធាន |
| ៣-ឯកឧត្តម | ហែម សំកុល | អនុរដ្ឋលេខាធិការក្រសួង អ.យ.ក | ជាសមាជិក |
| ៤-ឯកឧត្តម | សេង ហាក់ស្រុន | អនុរដ្ឋលេខាធិការក្រសួង ស.ខ.ល | ជាសមាជិក |
| ៥-លោក | កែវ គីមថុន | អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម | ជាសមាជិក |
| ៦-លោក | ហៀង វ៉ាសនា | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនិងជំនួយ | ជាសមាជិក |
| ៧-លោក | យី វ៉ាសនា | នាយកប្រតិបត្តិអង្គការ NCDP | ជាមាជិក |
| ៨-លោក | សុន សុងហាក់ | នាយកប្រតិបត្តិអង្គការ CDPO | ជាសមាជិក |
| ៩-អ្នកស្រី | សូ ចំរើន | តំណាងស្ត្រីពិការ អង្គការ CDPO | ជាសមាជិក |
| ១០-លោក | ស៊ុម សំបូរ | តំណាងមកពីអង្គការ HI | ជាសមាជិក |
| ១១-លោក | Kike Figaredo | តំណាងមកពីអង្គការ JR | ជាសមាជិក |

សមាជិកដែលពុំមានសិទ្ធបោះឆ្នោត រួមមាន : វេជ្ជបណ្ឌិត យួន អេងមុនី ក្រសួងសុខាភិបាល និង លោក អ៊ុក ម៉ានី ក្រសួងអប់រំយុវជននិងកីឡា ។